# ការប្រជុំជាមួយក្រុមជនជាតិភាគតិចនៅកម្ពុជា
# ការយល់ដឹងពីអំពើប្រល័យពូជសាសន៍ : ការពិត ការចងចាំ និងយុត្តិធម៌

វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០

## *តើអ្វីជាអំពើប្រល័យពូជសាសន៍?*
## *តើអ្វីជាចំណុចខ្វះខាតនៅក្នុងអនុសញ្ញាអំពើប្រល័យពូជសាសន៍?*
## *តើត្រូវទប់ស្កាត់អំពើប្រល័យពូជសាសន៍ដោយរបៀបណា?*

*សេចក្តីសង្ខេបអត្ថបទរបស់លោកសាស្ត្រាចារ្យ វីលៀម ស៊ីបាស់*

*អំពើប្រល័យពូជសាសន៍គឺជាទស្សនៈច្បាប់មួយ ។ ក៏ដូចជាការសម្លាប់ ការរំលោភសេពសន្ថវៈ និងចោរកម្មដែរ អំពើប្រល័យពូជសាសន៍ក៏ត្រូវបានគេយកទៅប្រើប្រាស់នៅក្នុងបរិបថផ្សេងៗ និងដោយការកំណត់ផ្សេងៗដែលធ្វើឲ្យអត្ថន័យរបស់វាមានភាពខុសប្លែកពីគ្នាដែរ ។ ប្រវត្តិវិទូ និង សង្គមវិទូ បានបកស្រាយអំពើប្រល័យពូជសាសន៍ថា ជាអំពើសាហាវឃោរឃៅមួយដែលមានជាប់ពាក់ព័ន្ធនឹងការសម្លាប់ប្រជាជនជាទ្រង់ទ្រាយធំ ។ ប៉ុន្តែនៅក្នុងច្បាប់ វាមិនមានភាពច្បាស់លាស់ ក្នុងការលើកឡើងពីអត្ថន័យតែមួយនៃអំពើប្រល័យពូជសាសន៍ ដែលត្រូវបានគេទទួលស្គាល់នៅលើពិភពលោកទេ ។ អំពើប្រល័យពូជសាសន៍មាននិយមន័យមួយដែលគេទទួលស្គាល់ ហើយមានចែងនៅក្នុងមាត្រា២ នៃអនុសញ្ញាស្តីពីការបង្ការ និងការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ ដូចនិយមន័យច្បាប់ភាគច្រើនដែរ ភាសានៃអំពើប្រល័យពូជសាសន៍អាចត្រូវបានគេយកទៅបកស្រាយខុសៗគ្នា ប៉ុន្តែទោះបីជាវាមាននិយមន័យច្បាស់លាស់ក៏ដោយ បញ្ហាចម្រូងចម្រាស់គឺវិសាលភាពនៃទស្សនៈនោះ ។*

*ពាក្យប្រល័យពូជសាសន៍ត្រូវបានបង្កើតឡើងដោយមេធាវីម្នាក់ ដែលមានឈ្មោះថា រ៉ាហ្វល់ លេមឃីន ។ គាត់មានបំណងបំពេញចំណុចខ្វះខាតរបស់ច្បាប់អន្តរជាតិដោយក្រោយមកគាត់បានធ្វើឲ្យវាលេចជារូបរាងនៅថ្ងៃបញ្ចប់នៃសង្គ្រាមលោកលើកទីពីរ ។ នៅក្នុងរយៈពេលជាងពីរទសវត្សរ៍ លេមឃីនបានធ្វើការទាក់ទងនឹងកិច្ចការងាររកម្រិតអន្តរជាតិដើម្បីកំណត់ក្រុមនៃឧក្រិដ្ឋកម្មអន្តរជាតិដែលពាក់ព័ន្ធនឹងអំពើសាហាវឃោរឃៅប្រឆាំងនឹងប្រជាជនស៊ីវិលដែលងាយនឹងទទួលគ្រោះថ្នាក់ ។ នៅមុនពេល លេមឃីន បង្កើតនិយមន័យនោះ ច្បាប់អន្តរជាតិបានទទួលស្គាល់ឧក្រិដ្ឋកម្មអន្តរជាតិមួយចំនួនតូចប៉ុណ្ណោះ ។ នៅក្នុងវិធានទូទៅ វាត្រូវបានគេគាក់តែងឡើងមិនមែនដោយសារតែទំហំនៃភាពសាហាវឃោរឃៅនិងការរីករាលដាលរបស់វាទេ គឺដោយសារតែវាហួសពីយុត្តាធិការរបស់ប្រទេស ។ ការប្លន់តាមសមុទ្រ*

គឺជាឧទាហរណ៍មួយនៃឧក្រិដ្ឋកម្មប្រព្រឹត្តនៅលើផ្ទៃសមុទ្រ ។ លេមឃីន និងអ្នកដទៃទៀតបានប្រើអំណះអំណាងរៀងៗខ្លួនទៅតាមទស្សនៈផ្សេងគ្នា ដើម្បីស្នើឲ្យមានការទទួលស្គាល់ឧក្រិដ្ឋកម្មអន្តរជាតិដែលតំណាងឲ្យការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្ស ។

ការចាប់ផ្តើមនេះបានចេញជារូបរាងច្បាស់នៅក្នុងសង្គ្រាមលោកលើកទីមួយគឺ នៅពេលដែលប្រទេសអង់គ្លេស បារាំង និងរុស្ស៊ីបានព្រមានថាខ្លួននឹងដាក់ឲ្យជនដៃដល់ទទួលខុសត្រូវចំពោះ«ឧក្រិដ្ឋកម្មថ្មីដែលទួគីធ្វើទៅលើប្រជាជនស៊ីវិល» ។ ប៉ុន្តែទស្សនៈដែលថាប្រទេសមួយត្រូវទទួលខុសត្រូវចំពោះអំពើសាហាវឃោរឃៅដែលបានធ្វើទៅលើប្រជាជនខ្លួនឯងនៅតែជាបញ្ហាចម្រូងចម្រាស់មួយ ដូច្នេះវាគឺជាចំណុចខ្វះខាតនៅក្នុងច្បាប់ដែល លេមឃីន ត្រូវបំពេញ ។

## អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

ទស្សនៈច្បាប់នៃអំពើប្រល័យពូជសាសន៍ត្រូវបានបង្កើតឡើងនៅក្រោយសង្គ្រាមលោកលើកទីពីរដើម្បីកាត់ទោសអំពើព្រៃផ្សៃរបស់ណាហ្ស៊ី ។ ការវិវឌ្ឍន៍របស់វាកើតឡើងជាមួយនឹងការវិវឌ្ឍន៍របស់ឧក្រិដ្ឋកម្មអន្តរជាតិផ្សេងទៀតជាពិសេសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានទំនាក់ទំនងជិតស្និទ្ធប៉ុន្តែស្មុគស្មាញនិងពិបាក ។ យើងនឹងមិនយល់ពីការវិវឌ្ឍន៍និងប្រវត្តិសាស្ត្រស្តីពីអំពើប្រល័យពូជសាសន៍ក្នុងទស្សនៈច្បាប់ប្រសិនបើយើងមិនបានពិចារណាទៅលើវត្តមានរបស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

ទោះបីជាអ្នកចូលរួមក្នុងគណៈកម្មាការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិដែលបានបង្កើតឡើងនៅខែវិច្ឆិកា ឆ្នាំ១៩៤៣ និងសន្និសីទនៅទីក្រុងឡុងដ៍ពីចុងខែមិថុនា ដល់ដើមខែសីហា ឆ្នាំ១៩៤៥ ដើម្បីរៀបចំតុលាការកាត់ទោសឧក្រិដ្ឋកម្មសង្គ្រាមនៅនូរ៉ែមប៊ឺកបានជ្រើសរើសពាក្យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដើម្បីធ្វើការចោទប្រកាន់ គេក៏បានចាត់ទុកថា ពាក្យប្រល័យពូជសាសន៍មានន័យស្រដៀងនឹងគ្នាដែរ ។ តុលាការយោធាអន្តរជាតិបានចោទប្រកាន់ចុងចោទណាហ្ស៊ីពីបទប្រព្រឹត្តអំពើប្រល័យពូជសាសន៍ដោយចេតនានិងជាប្រព័ន្ធដែលរួមមានការសម្លាប់ផុតពូជនូវក្រុមជាតិនិងពូជសាសន៍ប្រឆាំងនឹងប្រជាជនស៊ីវិលដែលរស់នៅក្នុងតំបន់កាន់កាប់ដើម្បីកំចាត់ពូជសាសន៍និងវណ្ណៈរបស់ប្រជាជននិងក្រុមជាតិ ពូជសាសន៍ ឬសាសនា ដូចជាជនជាតិជ្វីហ្វ ប៉ូលស៍ និងជីបស៊ីស៍ ។ ពាក្យប្រល័យពូជសាសន៍ជានិច្ចជាកាលត្រូវបានព្រះរាជអាជ្ញាយកមកប្រើប្រាស់នៅអំឡុងពេលជំនុំជម្រះក្តី ។ក្រោយមក លេមឃីន បាននិយាយថា«ភ័ស្តុតាងនៅក្នុងសវនការបានឆ្លើយតបទាំងស្រុងនូវទស្សនៈប្រល័យពូជសាសន៍ ។

ទោះបីជាយ៉ាងណាក៏ដោយ ធម្មនុញ្ញតុលាការយោធាអន្តរជាតិមិនបានប្រើប្រាស់ពាក្យប្រល័យពូជសាសន៍ ហើយពាក្យនេះក៏មិនបានលេចឡើងនៅក្នុងសេចក្តីសម្រេចចុងក្រោយដែលចេញនៅថ្ងៃទី

៣០ ខែកញ្ញា និងថ្ងៃទី១ ខែតុលា ឆ្នាំ១៩៤៦ដែរ ។ ដូចដែលបានកំណត់ដោយតុលាការនៅនូរ៉េមប៊ឺក ទស្សនៈច្បាប់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមានដែនកំណត់ជាក់លាក់មួយគឺថា វាត្រូវបានគេកំណត់ទំហំមកត្រឹមជាអំពើព្រៃផ្សៃដែលប្រព្រឹត្តឡើងនៅក្នុងសង្គ្រាម ។ វាត្រូវបានបង្កើតឡើងទៅតាមចេតនារបស់អ្នកព្រាងបទបញ្ញត្តិច្បាប់គ្រប់គ្រងទៅលើការចោទប្រកាន់ ជាពិសេស មហាអំណាចទាំងបួនគឺ សហរដ្ឋអាមេរិក ចក្រភពអង់គ្លេស បារាំង និងសហភាពសូវៀត ។ ជាងនេះទៅទៀត ការពង្រីកច្បាប់អន្តរជាតិពីឧក្រិដ្ឋកម្មសង្គ្រាមមានជាប់ពាក់ព័ន្ធនឹងបទល្មើសសង្គ្រាម និងទម្រង់ផ្សេងៗនៃការធ្វើទុក្ខបុកម្នេញទៅលើប្រជាជនប្រជាជនស៊ីវិលនៅក្នុងតំបន់ដែលកាន់កាប់ ដូច្នេះទើបវាអាចគ្របដណ្តប់លើអំពើសាហាវឃោរឃៅ ដែលប្រព្រឹត្តដោយរដ្ឋាភិបាលប្រឆាំងនឹងប្រជាជនស៊ីវិល និងគម្រាមដល់ប្រទេសដែលកំពុងតែរៀបចំការធ្វើទុក្ខបុកម្នេញ ។

ដោយនិយាយអំពីឧក្រិដ្ឋកម្មនៃការសម្លាប់ ការធ្វើទុក្ខបុកម្នេញ និងការនិរទេសដោយហេតុផលនយោបាយ ពូជសាសន៍ ឬសាសនាដែលអាចហៅថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចាស៊ីស ជែកសុនបានបង្ហាញពីប្រភពនៃការព្រួយបារម្ភរបស់រដ្ឋាភិបាលរបស់លោកថា ៖

តាមធម្មតា យើងមិនពិចារណាថា សកម្មភាពរបស់រដ្ឋាភិបាលទៅលើប្រជាពលរដ្ឋខ្លួនឯងសក្តិសមនឹងឲ្យយើងធ្វើការជ្រៀតជ្រែកទេ ។ យើងធ្លាប់ជួបប្រទះស្ថានភាពគួរឲ្យសោកស្តាយកើតឡើងនៅក្នុងប្រទេស ដែលនៅពេលនោះប្រជាជនភាគតិចនៅក្នុងប្រទេសត្រូវទទួលការធ្វើបាប ។ យើងគិតថាវាមានភាពស្របច្បាប់ដែលយើងធ្វើអន្តរាគមន៍ ឬព្យាយាមផ្តល់យុត្តិធម៌តាមរយៈការកាត់ទោសដល់បុគ្គលឬប្រទេសណាមួយ ពីព្រោះជំរំប្រមូលផ្តុំនិងការនិរទេសគឺដើរទៅតាមផែនការមួយ ឬការបង្កើតសង្គ្រាមខុសច្បាប់ដែលធ្វើឲ្យយើងមានជាប់ពាក់ព័ន្ធ ។ យើងមិនមានមូលដ្ឋានផ្សេង ដែលអាចឲ្យយើងជ្រៀតជ្រែកលើអំពើសាហាវឃោរឃៅដែលប្រព្រឹត្តឡើងនៅក្នុងប្រទេសអាល្លឺម៉ង់ក្រោមច្បាប់អាល្លឺម៉ង់ ឬសូម្បីការរំលោភទៅលើច្បាប់អាល្លឺម៉ង់ដោយអាជ្ញាធរប្រទេសអាល្លឺម៉ង់ទេ ។

មិនមានអ្វីគួរឲ្យសង្ស័យទេថា ប្រទេសអង់គ្លេស បារាំង និង សូវៀត មានមូលហេតុផ្ទាល់ខ្លួនដែលធ្វើឲ្យប្រទេសទាំងនេះមានបញ្ហាដូចគ្នា ។ សរុបមក និយមន័យនៃពាក្យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងមាត្រា៦(គ) នៃធម្មនុញ្ញនូរ៉េមប៊ឺក ទាមទារឲ្យអំពើសាហាវឃោរឃៅទាំងឡាយនោះត្រូវបានប្រព្រឹត្តឡើង«ដោយមានការជួយជ្រោមជ្រែងឬមានទំនាក់ទំនងជាមួយនឹងឧក្រិដ្ឋកម្មណាមួយ ដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការអន្តរជាតិ» ។ នៅក្នុងសេចក្តីសម្រេចចុងក្រោយរបស់ខ្លួន តុលាការយោធាអន្តរជាតិបានធ្វើការបែងចែក រវាងការធ្វើទុក្ខបុកម្នេញទៅលើជនជាតិជ្វីហ្វនៅអាល្លឺម៉ង់នៅមុនពេលសង្គ្រាមដែលមានលក្ខណៈ «ធ្ងន់ធ្ងរនិងគាបសង្កត់ខ្លាំង» និងគោលនយោបាយរបស់អាល្លឺម៉ង់នៅ

អំឡុងពេលសង្គ្រាមដែលស្ថិតនៅក្រោមការត្រួតត្រារបស់ខ្លួន ។ ទោះបីជាសេចក្តី សម្រេចនេះសំដៅទៅលើព្រឹត្តការណ៍ដែលកើតមានឡើងក្នុងអំឡុងទសវត្សរ៍៣០ ក៏មិនមានជនសង្ស័យណាម្នាក់ត្រូវបានរកឃើញថាមានទោសពីអំពើដែលបានប្រព្រឹត្តឡើងមុនខែកញ្ញា ឆ្នាំ១៩៣៩ ដែលជាសម័យសង្គ្រាម ។

ក្រោយពីមានសេចក្តីសម្រេចនេះមានការផ្ទុះឡើងយ៉ាងធ្ងន់ធ្ងរអំពីការដាក់កម្រិតទៅលើទស្សនៈនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ សេចក្តីខកបំណងនោះ បានសម្តែងចេញមកដោយខ្លួនឯងនៅពេលដែលមានការប្រជុំនៅមហាសន្និបាតអង្គការសហប្រជាជាតិនៅទីក្រុងឡុងដ៍នៅពេលនោះ ។ ប្រទេសឥណ្ឌា គុយបា និងប៉ាណាម៉ា បានធ្វើការសម្រេចជាផ្លូវការមួយដើម្បីដោះស្រាយភាពខុះខាតរបស់សវនាការនូរ៉ែមប៊ឺគនេះ ដោយកំណត់ថាជាអំពើទាំងឡាយណាដែលប្រព្រឹត្តឡើងមុនសង្គ្រាមនឹងត្រូវទុកចោលមិនយកមកធ្វើការវិនិច្ឆ័យទេ ។ សេចក្តីសម្រេចដែលបានធ្វើឲ្យអ្នកចាប់ផ្តើមដំណើរការពីដំបូងអស់សេចក្តីសង្ឃឹមបានចាប់ផ្តើមដំណើរការមួយដែលត្រូវបានសម្រេចនៅពីរឆ្នាំក្រោយមក នៅពេលដែលមានការអនុម័តនូវអនុសញ្ញាស្តីពីការទប់ស្កាត់ និងការដាក់ទណ្ឌកម្មទៅលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ សំណើឲ្យដាក់អនុសញ្ញាប្រល័យពូជសាសន៍ជាសម្អាងយោងទៅលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិថា ជាទស្សនៈមានការទំនាក់ទំនងគ្នាប្កជាឆ័ត្រមួយទូលាយដែលអាចឲ្យឧក្រិដ្ឋកម្មប្រល័យពូជសាសន៍អាចជ្រកជ្រៀតបាននោះ ត្រូវបានបដិសេធចោលដោយអ្នកធ្វើសេចក្តីព្រាងដើម្បីកុំឲ្យមានការច្របូកច្របល់អំពីរឿងដែលថា អំពើប្រល័យពូជសាសន៍អាចប្រព្រឹត្តឡើងនៅក្នុងពេលសន្តិភាព ក៏ដូចជាក្នុងពេលសង្គ្រាម ។ នេះមិនអាចនិយាយឲ្យច្បាស់លាស់អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនាពេលនោះទេ ជាក់ស្តែងដោយហេតុតែមានតុលាការ នូរ៉ែមប៊ឺក ពីមុនមក ។

ដូច្នេះការទទួលស្គាល់អំពើប្រល័យពូជសាសន៍ថាជាឧក្រិដ្ឋកម្មអន្តរជាតិដោយមហាសន្និបាតរបស់អង្គការសហប្រជាជាតិនៅឆ្នាំ១៩៤៦ ហើយនឹងការប្រមូលជាក្រមអនុសញ្ញានៅឆ្នាំ១៩៤៨ អាចត្រូវបានយល់ថា ជាប្រតិកម្មទៅនឹងប្រកបង្វៀតទៅកាន់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងសាលក្រមនូរ៉ែមប៊ឺកនៃតុលាការយោធាអន្តរជាតិ ។ នេះគឺជាភាពបរាជ័យរបស់តុលាការនូរ៉ែមប៊ឺតដែលមិនបានទទួលស្គាល់ថាឧក្រិដ្ឋកម្មដ៏សាហាវឃោរឃៅនេះជាឧក្រិដ្ឋកម្មអន្តរជាតិ ដែលបានប្រព្រឹត្តឡើងនៅក្នុងពេលសន្តិភាព និងដែលធ្វើឲ្យមានការផ្តួចផ្តើមគំនិតទទួលស្គាល់ និងកំណត់និយមន័យឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ ប្រសិនបើតុលាការនូរ៉ែមប៊ឺក អាចអះអាងថាឧក្រិដ្ឋកម្មដែលប្រព្រឹត្តនៅក្នុងពេលសន្តិភាពពិតជាបានចាត់ចូលទៅក្នុងច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិមែននោះ អនុសញ្ញាអំពើប្រល័យពូជសាសន៍ក៏ប្រហែលជាមិនបានសម្រេចបង្កើតដែរ ។ ពាក្យថា “អំពើប្រល័យពូជសាសន៍” ប្រហែលជានឹងនៅ

តែជាពាក្យដ៏មានប្រជាប្រិយភាពឬពាក្យដែលមិនផ្លូវការ ប្រើប្រាស់ដោយអ្នកកាសែត អ្នកប្រវត្តិសាស្ត្រ និងអ្នកវិទ្យាសាស្ត្រសង្គម ប៉ុន្តែប្រហែលជាគេមិនប្រើប្រាស់ផ្នែកផ្លូវច្បាប់ទេ ។

## អនុសញ្ញាអំពើប្រល័យពូជសាសន៍ឆ្នាំ១៩៤៨

អនុសញ្ញានៃការទប់ស្កាត់និងការដាក់ទណ្ឌកម្មទៅលើអំពើប្រល័យពូជសាសន៍ត្រូវបានបង្កើតឡើងដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៤៨ ។ អនុសញ្ញានេះបានឲ្យនិយមន័យអំពើប្រល័យពូជសាសន៍ថា ៖

នៅក្នុងអនុសញ្ញាបច្ចុប្បន្នអំពើប្រល័យពូជសាសន៍គឺជា អំពើទាំងឡាយណាដែលប្រព្រឹត្តឡើងក្នុងបំណងបំផ្លិចបំផ្លាញទាំងស្រុងឬដោយផ្នែកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនាណាមួយដូចជា ៖

ក) ការធ្វើមនុស្សឃាតទៅលើសមាជិកនៃក្រុម

ខ) ការធ្វើឲ្យរបួសយ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ ឬ សតិបញ្ញាសមាជិកនៃក្រុម

គ) ការធ្វើដោយចេតនាឲ្យក្រុមនេះទទួលរងនូវស្ថានភាពរស់នៅមួយដែលបានរៀបចំឡើងសម្រាប់បំផ្លិចបំផ្លាញរាងកាយទាំងស្រុង ឬ មួយផ្នែក

ឃ) ការដាក់នូវវិធានការនានាដែលមានបំណងរារាំងមិនឲ្យមានការផ្ដល់កំណើតទារក

ង) ការបញ្ជូនកុមារដោយបង្ខំពីក្រុមមួយទៅក្រុមមួយផ្សេងទៀត

## ក្រុមដែលត្រូវទទួលបានការការពារ

យោងតាមអនុសញ្ញាឆ្នាំ១៩៤៨ និយមន័យនៃ "ក្រុមដែលត្រូវបានការពារ" សំដៅទៅលើ "ក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ និងសាសនា ។ នៅក្នុងអំឡុងពេលអនុម័តអនុសញ្ញាអំពើប្រល័យពូជសាសន៍ទស្សនៈនេះមានលក្ខណៈស្រដៀងគ្នានឹងទស្សនៈ ដែលគេចាត់ទុកជា "ក្រុមជនជាតិភាគតិច" ។ នេះគឺជាទស្សនៈរបស់លោក រ៉ាហ្វែល លេមឃីន និងអ្នកប្រាជ្ញអន្តរជាតិម្នាក់ទៀតដែលបានជួយសហរដ្ឋអាមេរិកតាក់តែងសេចក្ដីព្រាងលើកដំបូងនៃអនុសញ្ញានេះ ។ ក្នុងអំឡុងកិច្ចចរចាមានការជជែកពិភាក្សាដ៏សំខាន់មួយស្ដីពីបញ្ហាថាតើគួរតែដាក់បញ្ចូលក្រុមនយោបាយនៅក្នុងនិយមន័យនេះឬយ៉ាងណា ។ ការធ្វើទុក្ខបុកម្នេញលើសមាជិកនយោបាយត្រូវបានទទួលស្គាល់ថាជា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅទីក្រុងនូរ៉េមប៊ឺក ។ ប៉ុន្តែ អ្នកធ្វើសេចក្ដីព្រាងអនុសញ្ញាអំពើប្រល័យពូជសាសន៍ ដូចជាលោក លេមឃីន ជាដើមបានបដិសេធដាច់ខាតនូវការដាក់បញ្ចូលក្រុមនយោបាយ ។ អត្ថបទបន្តបន្ទាប់ទាក់ទងនឹងបញ្ហា

នេះ បានអះអាងថាការមិនដាក់បញ្ចូលក្រុមនយោបាយ ទៅក្នុងនិយមន័យអំពើប្រល័យពូជសាសន៍គឺជាលទ្ធផលដែលបណ្ដាលមកពីការដាក់សម្ពាធរបស់សហភាពសូវៀត ប៉ុន្តែការអានដោយយកចិត្តទុកដាក់លើអត្ថន័យ និងកំណត់ហេតុនៃសេចក្តីព្រាងបានបង្ហាញឲ្យឃើញថាការប្រឆាំងមិនទទួលស្គាល់គំនិតដាក់បញ្ចូលក្រុមនយោបាយនេះមានលក្ខណៈទូលំទូលាយ ។

## ការបោសសម្អាតជាតិពន្ធុ និងអំពើប្រល័យពូជសាសន៍លើផ្នែកវប្បធម៌

ខណៈពេលដែលអនុសញ្ញាអំពើប្រល័យពូជសាសន៍កំពុងត្រូវបានព្រាងទង្វើដែលអាចផ្តន្ទាទោសបានត្រូវបែងចែកជាបីផ្នែកគឺ អំពើប្រល័យពូជសាសន៍លើផ្នែករូបរាងកាយ ជីវសាស្ត្រ និងវប្បធម៌ ។ មហាសន្និបាតអង្គការសហប្រជាជាតិបានបោះឆ្នោតសម្រេចមិនដាក់បញ្ចូលអំពើប្រល័យពូជសាសន៍លើផ្នែកវប្បធម៌ចូលទៅក្នុងអនុសញ្ញាអំពើប្រល័យពូជសាសន៍នេះឡើយ ។ ហើយក៏បានច្រានចោលនូវការទាមទារឲ្យធ្វើវិសោធនកម្មពីសំណាក់ប្រទេសស៊ីរៀឲ្យដាក់បញ្ចូលទង្វើនៃអំពើប្រល័យពូជសាសន៍ដែលសព្វថ្ងៃអាចទុកថាជា«ការបោសសម្អាតជាតិពន្ធុ» ។ នៅពេលដែលសន្និបាតអង្គការសហប្រជាជាតិយល់ព្រមដាក់បញ្ចូលការបញ្ជូនកុមារពីកន្លែងមួយទៅកន្លែងមួយដោយបង្ខំ ដែលអាចធ្វើឲ្យមានការលុបបំបាត់ក្រុមនោះត្រូវបានចាត់ទុកថា ជាការលុបបំបាត់ការចងចាំផ្នែកវប្បធម៌និងភាសាជាតិតាមរយៈការដាក់បញ្ចូលក្រុមនោះជាមួយក្រុមដទៃទៀត នៅពេលដែលក្រុមនោះមានអាយុក្មេងវាគឺជាករណីលើកលែងមួយចំពោះការមិនរាប់បញ្ចូលអំពើប្រល័យពូជសាសន៍លើផ្នែកវប្បធម៌ ។

ការផ្អែកលើប្រវត្តិនៃសេចក្តីព្រាងអនុសញ្ញានេះ ទំនងជាបញ្ញប់បញ្ញត្តិនេះដោយរារាំងមិនឲ្យសេចក្តីព្រាងធ្វើការវិវត្តន៍ទៅមុខបានគឺ ដើម្បីទុកពេលពិចារណាឡើងវិញលើប្រវត្តិនៃការវិវត្តន៍ និងឥរិយាបថផ្លាស់ប្តូររបស់សេចក្តីព្រាងអនុសញ្ញានេះ ។ យើងអាចនិយាយបានថាតុលាការសព្វថ្ងៃនេះបានបង្ហាញការគោរពតាមទស្សនៈដ៏តូចចង្អៀតដែលអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិកាលពីឆ្នាំ១៩៤៨ ។ យ៉ាងណាមិញ បញ្ហានេះត្រូវបានយកមកពន្យល់បកស្រាយដោយមិនលម្អៀងនៅក្នុងការពិភាក្សា ។ ដូចនឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែលបានលេចឡើងនៅក្នុងច្បាប់អន្តរជាតិដើម្បីធ្វើជាប្រតិកម្មទៅនឹងល័ក្ខខ័ណ្ឌកំណត់របស់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ បច្ចុប្បន្ននេះច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិបានវិវត្តន៍ទៅរកដំណាក់កាលដែលថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនេះអាចរួមបញ្ចូលទាំងទង្វើកម្ចាត់ជាតិពន្ធុ និងអំពើប្រល័យពូជសាសន៍លើផ្នែកវប្បធម៌ ទោះបីជាឧក្រិដ្ឋកម្មនោះត្រូវបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលមានសន្តិភាពក៏ដោយ ។ ជាលទ្ធផល មិនមាន "ចន្លោះ

និទ្ទុណ្ឌភាព» ហើយក៏ស៊ើរតែគ្មានសម្ពាធលើផ្នែកច្បាប់ទាក់ទិននឹងការពង្រីកនិយមន័យនៃអំពើប្រល័យពូជសាសន៍នេះតាមរយៈការបកស្រាយខាងលើ ។ សិទ្ធិដាច់មុខខាងផ្នែកនយោបាយ និងនិមិត្តរូបនិយមមានជាប់ពាក់ព័ន្ធនឹងពាក្យ «អំពើប្រល័យពូជសាសន៍» ហើយមានជនរងគ្រោះជាច្រើនខកចិត្តយ៉ាងខ្លាំងនៅពេលដែលទុក្ខវេទនារបស់ខ្លួនត្រូវបានចាត់ទុកថា ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ «តែមួយ» ។ អ្នកទាំងនោះមិនកោតសរសើរសារសំខាន់នៃភាពខុសគ្នារបស់ច្បាប់ប៉ុន្មានទេ ពីព្រោះវាបានបណ្តាលឲ្យមានការវិភាគវែកញែកពីប្រវត្តិសាស្រ្តដ៏ស្មុគស្មាញ ។ ដូច្នេះ បើទោះបីជាភាពខុសគ្នារវាងអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មិនផ្តល់ជាលទ្ធផលសំខាន់តាមផ្លូវច្បាប់ក៏ដោយ ក៏ភាពខុសគ្នារវាងពាក្យទាំងពីរនេះនៅតែមានសារសំខាន់នៅក្នុងបរិបទផ្សេងទៀតដែរ ។

## សេចក្តីបញ្ចប់

អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍នៅតែបន្តធ្វើឲ្យអ្នកជំនាញច្បាប់ អ្នកនយោបាយ អ្នកយកព័ត៌មាននិងសកម្មជនសិទ្ធិមនុស្សទាំងអស់មានការចាប់អារម្មណ៍ដដែល ។ ក្នុងអំឡុងពេលហាសិបឆ្នាំនេះ អនុសញ្ញានេះ នៅតែស្ថិតនៅក្នុងស្ថានភាពតានតឹងជាមួយនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដដែល ។ មានការមិនពេញចិត្តជាខ្លាំងទៅនឹងភាពតូចចង្អៀតនៃនិយមន័យពាក្យប្រល័យពូជសាសន៍ ។ អាស្រ័យហេតុនេះ មានមនុស្សជាច្រើនបានទាមទារឲ្យមានការបកស្រាយបែបទូលំទូលាយទាក់ទងនឹងទស្សនៈស្តីពីអំពើប្រល័យពូជសាសន៍ ដែលអាចរួមបញ្ចូលទាំងក្រុមទទួលបានការការពារផ្សេងទៀត ដូចជាក្រុមនយោបាយនិងសង្គម ហើយដែលអាចអនុវត្តមកលើបទល្មើសផ្សេងៗទៀតដែលទូលំទូលាយជាងនេះ ។ ប៉ុន្តែតាមការជាក់ស្តែង អ្វីដែលអ្នកទាំងនោះធ្វើការស្នើសុំគឺមានន័យថា ស្មើទៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលមិនមានជាប់ពាក់ព័ន្ធទៅនឹងជម្លោះប្រដាប់អាវុធ ។

នៅដើមឆ្នាំ១៩៨៥ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនិងអំពើប្រល័យពូជសាសន៍គឺកើតមកពីប្រភពតែមួយនោះទេ ហើយពាក្យនេះបង្កើតឡើងដើម្បីធ្វើការពិពណ៌នាពីបទល្មើសដ៏ឃោរឃៅព្រៃផ្សៃរបស់របបណាហ្ស៊ី ។ ទោះបីជាវិសាលភាពមិនមានភាពដូចគ្នាក៏ដោយ ពាក្យនេះក៏មានន័យជាន់គ្នាហើយអាចយកមកប្រើប្រាស់ជំនួសគ្នាបានទោះបីជាតិចក្តីច្រើនក្តី ដើម្បីពិពណ៌នាពីឧក្រិដ្ឋកម្មដ៏ធំធេងនៅពេលនោះ ដែលព្យាយាមធ្វើការកម្ទេចប្រជាជនជិហ្វនៅប៉ែកអឺរ៉ុបទាំងអស់ ។ នៅចុងឆ្នាំ១៩៨៦ មានការកើតឡើងនូវការមិនយល់ស្របគ្នាដ៏សំខាន់មួយ ហើយវាមិនត្រូវបានដោះស្រាយនោះទេរហូតទាល់តែចុងសតវត្សរ៍ឯនោះ ។

បច្ចុប្បន្ននេះ យើងប្រហែលជានិយាយពីពាក្យអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិម្តងទៀតដូច ដែលអ្វីដែលពាក្យនេះត្រូវបានប្រើប្រាស់កាលពីមុន ។ភាពខុសគ្នារវាងអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិគឺ នៅតែមានសារសំខាន់តែគ្រាន់តែជានិមិត្តរូបមួយតែប៉ុណ្ណោះ ។ មានប្រជាជនប៊ូស្នៀជាច្រើនមានការអស់សង្ឃឹមយ៉ាងខ្លាំងដោយសារតែការឈឺចាប់របស់អ្នកទាំងនោះ នៅអំឡុងសង្គ្រាមឆ្នាំ១៩៩២-១៩៩៥ នោះមិនត្រូវបានចាត់ទុកថាជាអំពើប្រល័យពូជសាសន៍នោះទេ លើកលែងតែនៅក្នុងករណីជាក់លាក់បំផុត និងជាចុងក្រោយគឺករណីនៃការសម្លាប់រង្គាលនៅ ស្រីព្រីនីកា តែប៉ុណ្ណោះ ។ ទោះបីជាយ៉ាងណាក៏ដោយ សេចក្តីសម្រេចដែលថាគ្មានគោលនយោបាយប្រល័យពូជសាសន៍ណាត្រូវបានដើរតាម ឬអនុវត្ត មិនគួរត្រូវបានបោកបញ្ឆោតនៅគ្រប់មធ្យោបាយណាទាំងអស់ដើម្បីបន្ថយភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលប្រព្រឹត្តបទល្មើសអន្តរជាតិដូចជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ដែលបានប្រព្រឹត្តឡើងប្រហែលជាមិនមែនមានភាពធ្ងន់ធ្ងរ និងឃោរឃៅតិចជាងអំពើប្រល័យពូជសាសន៍នោះទេ ។